PPCBank

# របាយការណ៍ប្រចាំត្រីមាសទី៤

(ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២)

## ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (លានរៀល) | ត្រីមាសទី៤ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|
| ទ្រព្យសកម្មសរុប | ៤.០៤៣.៥៣០ | ៤.០១៥.០៤១ |
| បំណុលសរុប | ៣.២៣៨.០៣៨ | ៣.៣០៦.៨១៧ |
| មូលធនសរុប | ៨០៥.៤៩២ | ៧០៨.២២៤ |
| **លទ្ធផលហិរញ្ញវត្ថុ (លានរៀល)** | **ត្រីមាសទី៤ឆ្នាំ២០២២** | **ត្រីមាសទី៤ឆ្នាំ២០២១** |
| ចំណូលសរុប | ៨១.១៥១ | ៧៩.៣០៦ |
| ចំណេញ(ខាត)មុនបង់ពន្ធ | ២៥.៦៦៨ | ២៩.៤១៤ |
| ចំណេញ(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ | ២០.៥៩៨ | ២៣.៤៤៧ |
| លទ្ធផលម្អិតក្នុងការិយបរិច្ឆេទ | ២០.៥០៩ | ២៣.១៤៦ |
| **អនុបាតហិរញ្ញវត្ថុ(%)** | **ត្រីមាសទី៤ឆ្នាំ២០២២** | **ឆ្នាំ២០២១** |
| អនុបាតសាធនភាព ❶ | ២១,៨១ | ១៩,១៩ |
| អនុបាតបំណុលធៀបនឹងមូលធន | ៤០២,០០ | ៤៦៦,៩២ |
| អនុបាតក្របខ័ណ្ឌសន្ទនីយភាព ❶ | ១២៧,៤៦ | ១២៥,៤៦ |
| អនុបាតឥណទានមិនដំណើរការ ❷ | ៤,៦១ | ១,៨២ |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ១០៥,០៣ | ៩៧,០៨ |
| **អនុបាតផលចំណេញ(%)** | **ត្រីមាសទី៤ឆ្នាំ២០២២** | **ត្រីមាសទី៤ឆ្នាំ២០២១** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម (ROA) | ២,០១ | ២,២៩ |
| អនុបាតចំណេញធៀបនឹងមូលធន (ROE) | ១០,១០ | ១២,៩៧ |
| អនុបាតលទ្ធភាពបង់ប្រាក់ | ៧៤៥,១៧ | ៨៦០,៧៤ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | មិនមាន | មិនមាន |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | មិនមាន | មិនមាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | មិនមាន | មិនមាន |

សំគាល់ :

❶ : អនុលោមទៅតាមបទបញ្ញត្តិគណនេយ្យដែលចេញដោយធនាគារជាតិនៃកម្ពុជា

❷ : ឥណទានមិនដំណើរការអនុលោមទៅតាមបទបញ្ញត្តិគណនេយ្យដែលចេញដោយធនាគារជាតិនៃកម្ពុជាចំណាត់ថ្នាក់សំវិធានធន ២០% - ១០០%

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប









# សមាសភាពក្រុមប្រឹក្សាភិបាល



**YIM, Yong Taick**

ប្រធានក្រុមប្រឹក្សាភិបាល



**SIM, Sang Ton**

សមាជិក



**Kim, Sung Chul**

សមាជិក



**HONG, Jee Soo**

សមាជិកឯករាជ្យ



**LEE, Myunsang**

សមាជិកឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយជាខ្លាំង ក្នុងការបង្ហាញជូននូវប្រតិបត្តិការហិរញ្ញវត្ថុរបស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ក្នុងត្រីមាសទី៤ ឆ្នាំ២០២២ ដោយអនុវត្តតាមការតម្រូវរបស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក) ។

ការធ្វើសមាហរណកម្មប្រកបដោយប្រសិទ្ធភាពនៃវ៉ាក់សាំងនៅក្នុងប្រទេសកម្ពុជាបាននាំមកនូវការសង្គ្រោះជីវិត ការបង្រួបបង្រួមប្រព័ន្ធថែទាំសុខភាព និងការរួមចំណែកដល់វឌ្ឍន៍ភាពជាតិឆ្ពោះទៅរកការស្តារសេដ្ឋកិច្ចឡើងវិញយ៉ាងឆាប់រហ័ស។ ការឆ្លើយតបយ៉ាងឆាប់រហ័សរបស់រដ្ឋាភិបាលកម្ពុជាបើប្រៀបធៀបទៅនឹងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត គឺប្រកបដោយភាពជោគជ័យក្នុងការកាត់បន្ថយវិបត្តិដែលបង្កឡើងដោយ កូវីដ-១៩ ។ ការផ្ទុះឡើងត្រូវបានគ្រប់គ្រងបានល្អ ហើយផលប៉ះពាល់អវិជ្ជមានដែលបណ្តាលមកពីជំងឺរាតត្បាតត្រូវបានកាត់បន្ថយ។

កម្ពុជាត្រូវបានគេរំពឹងថានឹងមានកំណើនសេដ្ឋកិច្ចប្រហែល ៥,៤% សម្រាប់ឆ្នាំ ២០២២ ហើយវាត្រូវបានព្យាករណ៍ថានឹងមាន ៦,៦% ក្នុងឆ្នាំ ២០២៣ នេះបើយោងតាមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា។ ធនាគារជាតិ នៃកម្ពុជា បានបញ្ជាក់ពីកំណើនជាក់ស្តែងគឺ ៥,១% នៅក្នុងការអភិវឌ្ឍវិស័យម៉ាក្រូសេដ្ឋកិច្ច និងធនាគារ នៅឆ្នាំ ២០២២។ យោងតាមធនាគារកណ្តាលកំណើននៅក្នុងប្រទេសកម្ពុជាត្រូវបានជម្រុញដោយការកើនឡើងនៃផ្នែកផលិតកម្ម ៩,៤% សណ្ឋាគារនិងភោជនីយដ្ឋានកើនឡើង ១៥,២% ការដឹកជញ្ជូនកើនឡើង ៦,១% និង ពាណិជ្ជកម្មលក់ដុំនិងលក់រាយកើនឡើង ៤,៥%។

ក្នុងអំឡុងត្រីមាសទី ៤ ឆ្នាំ២០២២ នេះ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានបង្កើតនិងបន្ថែមសេវាកម្មថ្មីៗទៀតជាច្រើនដូចជា សម្រាប់គណនីនិម្មិត ដែលអាចទទួលបានការទូទាត់ប្រាក់ពីគណនីបាគងបាន បន្ថែមមុខងារបន្ថែមទៀតលើសេវាធនាគារចល័ត សម្រាប់ដំណើរការផ្ទេរប្រាក់គំរូថ្មីបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវសេវាកម្មថ្មីមួយទៀត គឺម៉ាស៊ីន CRM ដែលអាចអោយអតិថិជនកាន់តែមានភាពងាយស្រួល និងរហ័សក្នុងការដាក់ប្រាក់ចូលក្នុងគណនីបានគ្រប់ពេលវេលា។ លើសពីនេះទៅទៀត នៅថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០២២ យើងក៏បានអនុវត្តការទូទាត់វិក្កយប័ត្របង់ទឹក

PPWSA (រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ) និង វិក្កយប័ត្របង់ភ្លើង EDC (អគ្គិសនីកម្ពុជា) នៅលើសេវាធនាគារតាមអ៊ីនធើណែត (Corporate Internet Banking) ដោយមិនគិតថ្លៃផងដែរ ។

ក្នុងនាមតំណាងក្រុមប្រឹក្សាភិបាល ខ្ញុំសូមយកឱកាសនេះថ្លែងអំណរគុណចំពោះភាគទុនិក ក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិរបស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក សម្រាប់ការណែនាំ និងភាពជាអ្នកដឹកនាំ និងក៏ដូចជាបុគ្គលិករបស់យើងដែលបានខិតខំប្រឹងប្រែង សម្រាប់ការរួមចំណែក និងការប្តេជ្ញាចិត្តរបស់ពួកគាត់ និងអរគុណចំពោះអតិថិជនដ៏មានតម្លៃរបស់យើងសម្រាប់ការបន្តការជឿទុកចិត្តរបស់ពួកគេមកលើ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ជាពិសេស ធនាគារជាតិ នៃ កម្ពុជា (NBC) និងនិយ័តករមូលប័ត្រកម្ពុជា (SERC) សម្រាប់ដំបូន្មាន និងការគាំទ្រ ។

ខ្ញុំ Yim Yong Taick សូមសម្តែងនូវការដឹងគុណចំពោះការខិតខំប្រឹងប្រែងដែលទទួលបានលទ្ធផលជោគជ័យក្នុងអំឡុងត្រីមាសទី ៤ ឆ្នាំ ២០២២ និងបន្តឆ្ពោះទៅរកអ្វីដែលយើងនឹងសម្រេចបាននៅក្នុងត្រីមាសខាងមុខជាបន្តបន្ទាប់ ។

ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣

ហត្ថលេខា និងត្រា

YIM. Yong Taick

ប្រធានក្រុមប្រឹក្សាភិបាល

# មាតិកា

**ព័ត៌មានហិរញ្ញវត្ថុសង្ខេប** ........ 1

**ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប** ........ 2

**សមាសភាពក្រុមប្រឹក្សាភិបាល** ........ 3

**សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល** ........ 4

**ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ** ........ 7

ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ........ 7

ខ. លក្ខណៈនៃធុរកិច្ច ........ 8

គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ 9

**ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** ........ 11

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក ........ 11

ខ. រចនាសម្ព័ន្ធចំណូល ........ 11

**ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ** ........ 12

**ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** ........ 13

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ 13

ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ........ 15

គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ........ 18

ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ........ 18

ង. ផលប៉ះពាល់អតិផរណា ........ 18

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងហិរញ្ញវត្ថុ របស់រដ្ឋាភិបាល ........ 18

**ហត្ថលេខាអភិបាលរបស់ធនាគារភ្នំពេញពាណិជ្ជ ម.ក** ........ 19

# ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

## ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក** |
| ជាអក្សរឡាតាំង | **Phnom Penh Commercial Bank Plc.** |
| លេខកូដស្តង់ដារ | KH ២០០០១១១A46 |
| ទីស្នាក់ការ | អគារលេខ២១៧ មហាវិថីនរោត្តម<br>សង្កាត់ទន្លេបាសាក់ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | (+៨៥៥) ២៣ ៩០៩ ៩០៩/(+៨៥៥) ២៣ ៩៩៩ ៥០០ |
| គេហទំព័រ | www.ppcbank.com.kh |
| អ៊ីមែល | info@ppcb.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០១៥៧៩៤ ចុះថ្ងៃទី២០ មេសា ២០០៨ |
| លេខអាជ្ញាបណ្ណអាជីវកម្ម | B២៣ ចេញដោយធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី១៦ ធ្នូ ២០១៩ |
| សេចក្តីសម្រេចអនុញ្ញាតិនិងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | ១៩២/២០ គ.ម.ក./ស.ស.រ ចុះថ្ងៃទី០១កញ្ញា ២០២០ |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | លោក Baek Jongil |

## ខ. លក្ខណៈនៃធុរកិច្ច

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានចាប់ផ្តើមប្រតិបត្តិការធនាគារ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨ ដែលមានទីស្នាក់ការកណ្តាលស្ថិតនៅអគារលេខ២១៧ មហាវិថី ព្រះនរោត្តម (ផ្លូវលេខ ៤១) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ និងទទួលបានអាជ្ញាបណ្ណពេញលេញជាធនាគារពាណិជ្ជ។ នៅខែកញ្ញា ឆ្នាំ២០១៦ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានស្វាគមន៍សម្រាប់ការចាប់ផ្តើមថ្មីមួយជាមួយភាគទុនិកដ៏រឹងមាំគឺ Jeonbuk Bank Co., Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ JB Financial Group Co. Ltd.), ក្រុមហ៊ុន Apro Financial Co., Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន J&K Capital Co., Ltd. ដែលស្ថិតនៅក្រោម OK Financial Group) និងក្រុមហ៊ុន JB Woori Capital Co., Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ JB Financial Group Co., Ltd.) ដែលមានមូលដ្ឋានស្ថិតនៅប្រទេសកូរ៉េខាងត្បូង។

នៅពេលដែលយើងបន្តកិច្ចខំប្រឹងប្រែងរបស់យើងទៅមុខទៀតយើងក៏មិនភ្លេច និងអបអរសាទរចំពោះភាពជោគជ័យនាពេលកន្លងមក ក្នុងការបំពេញបាននូវតម្រូវការជាច្រើនរបស់អតិថិជនក្នុងផ្នែកសេវាធនាគារ និងខិតខំស្វែងរកវិធីសាស្ត្រនានា ដើម្បីលើកកម្ពស់គុណភាពសេវារបស់យើង គាំទ្រអតិថិជនរបស់យើងទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត។ គិតត្រឹមបំណាច់ ខែធ្នូ ឆ្នាំ២០២២ ទ្រព្យសកម្មសរុបមានចំនួន ៩៨២ លានដុល្លារអាមេរិក សាខាចំនួន២៣ទូទាំងប្រទេស និងម៉ាស៊ីន ATMs ចំនួន៧០ (ម៉ាស៊ីនATMs ផ្សេងៗទៀតកំពុងត្រូវបានពិចារណានៅទីតាំងសក្តានុពលក្នុងប្រទេសកម្ពុជា)។ បន្ថែមពីនោះ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក និងបន្តធ្វើការផ្តល់ជូនដល់អតិថិជននូវសេវាដែលមានលក្ខណៈងាយស្រួល និងធ្វើការគាំទ្រដោយបណ្តាញឌីជីថល ដែលធ្វើឲ្យអតិថិជនកាន់តែមានភាពងាយស្រួល ជាមួយនិងបទពិសោធន៍ធនាគារ។ អតិថិជនអាចធ្វើការទំនាក់ទំនងមកយើងតាមរយៈ Live Chat ក្នុងរយៈពេល២៤ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍ តាមរយៈបណ្តាញឌីជីថលទាំងអស់របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក។ លើសពីនេះទៅទៀត ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានបង្កើតមជ្ឈមណ្ឌលសហគ្រាសធុនតូច-មធ្យម (SME Center) ជាលើកដំបូងរបស់ខ្លួន ដែលនឹងផ្តល់នូវផលិតផល និងសេវាSME។ សហគ្រាសធុនតូច-មធ្យម នឹងត្រូវទទួលបាននូវសេវាពិគ្រោះយោបល់អាជីវកម្មផងដែរ។ ពួកយើងក៏បានពង្រីកនូវការិយាល័យ

បរទេស (Foreign Desk) មានដូចជា ការិយាល័យកូរ៉េ ជប៉ុន និងចិន ក៏ដូចជា ហ្គោលក្លឹប និងមជ្ឈមណ្ឌល SME ដែលនឹងផ្តល់នូវផលិតផល និងសេវា SME។ ពួកយើងពិតជាផ្តល់តម្លៃដល់អតិថិជនទាំងអស់ និងបន្តធ្វើការអភិវឌ្ឍផលិតផលសេវារបស់ពួកយើង ដើម្បីបម្រើជូនដល់អតិថិជនឲ្យបានល្អបំផុត។

## គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

ដើម្បីធ្វើឲ្យកាន់តែមានភាពងាយស្រួលដល់អតិថិជនដ៏មានតម្លៃរបស់យើង និងពង្រីកសកម្មភាពប្រតិបត្តិការអាជីវកម្មរបស់យើង ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានសម្រេចផ្លាស់ប្តូរទីតាំងសាខាទឹកថ្លាទៅទីតាំងថ្មីដែលមានលក្ខណៈអំណោយផលល្អជាងមុន។

ដោយសារយើងផ្តោតលើសេវាធនាគារដែលមានភាពងាយស្រួល យើងកំពុងព្យាយាមអភិវឌ្ឍន៍ដើម្បីនាំយកនូវមធ្យោបាយដែលល្អ និងងាយស្រួលសម្រាប់អតិថិជន ដើម្បីធ្វើឲ្យការប្រើប្រាស់សេវាធនាគារមានអារម្មណ៍កាន់តែងាយស្រួលឡើងៗ។ ដូច្នេះនៅថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ២០២២ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានបង្កើតសេវាកម្មថ្មីមួយសម្រាប់គណនីនិម្មិតដែលអាចទទួលបានការទូទាត់ភ្លាមៗតាមរយៈប្រព័ន្ធបាគង។ អតិថិជន និងសហគ្រាសដែលប្រើប្រាស់គណនីនិម្មិតរបស់យើងក្នុងការប្រមូលការទូទាត់សម្រាប់អាជីវកម្មរបស់ពួកគេអាចទទួលបានការទូទាត់ពីសមាជិកបាគងណាមួយបន្ថែមលើបណ្តាញ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ដែលមានស្រាប់។

ដើម្បីធ្វើឲ្យប្រសើរឡើងសម្រាប់ការអភិវឌ្ឍន៍ ដូច្នេះនៅថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០២២ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានអភិវឌ្ឍកែលម្អ សេវាធនាគារចល័ត (PPCBank Mobile) សម្រាប់មុខងារបន្ថែម និងដំណើរការផ្ទេរប្រាក់ថ្មីនៅលើ សេវាធនាគារចល័ត។

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ ការទូទាត់វិក្កយប័ត្របង់ទឹក PPWSA និងការទូទាត់វិក្កយប័ត្របង់ភ្លើង EDC បានដាក់អោយដំណើរការតាមប្រព័ន្ធអ៊ីនធើណែត និងដោយមិនគិតថ្លៃ។ អតិថិជនសាជីវកម្មអាចធ្វើការទូទាត់ PPWSA និង EDC តាមអ៊ីនធើណែតភ្លាមៗពី smartBiz ដោយមិនចាំបាច់ទៅដល់ទីកន្លែង ឬសូម្បីទៅសាខាដែលនៅជិតពួកគេបំផុត។

នៅថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០២២ ធនាគារភ្នំពេញ ពាណិជ្ជ ម.ក បានដាក់ឲ្យដំណើរការម៉ាស៊ីន CRM ជាផលិតផលថ្មី ដែលធ្វើឱ្យអតិថិជនកាន់តែមានភាពងាយស្រួល និងរហ័សក្នុងការដាក់ប្រាក់របស់ពួកគេចូលទៅក្នុងគណនីបានគ្រប់ពេលវេលា។

នៅថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០២២ ធនាគារភ្នំពេញ ពាណិជ្ជ ម.ក បានដាក់ឱ្យដំណើរការនូវ "ការភ្ជាប់គណនីប្រាក់រៀលទៅកាត" ដែលអាចឱ្យអ្នកមានគណនីប្រាក់រៀលអាចភ្ជាប់គណនីរបស់ពួកគេជាមួយប័ណ្ណឥណពន្ធ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក និងអាចធ្វើប្រតិបត្តិការតាមរយៈម៉ាស៊ីនអេធីអឹមបានគ្រប់ទីកន្លែង។

# ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក

| លទ្ធផលសម្រេចបានសំខាន់ៗ | ត្រីមាសទី៤ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|
| **ផ្នែកសេវាឥណទាន** | | |
| ចំនួនគណនីឥណទាន | ៨.៨៣៧ | ៧.៣០៨ |
| ឥណទានដុលសរុប (លានរៀល) | ៣.២០២.៩៨២ | ៣.០៣៧.៩៣១ |
| **ផ្នែកសេវាប្រាក់បញ្ញើ** | | |
| ចំនួនគណនីប្រាក់បញ្ញើ | ១៤៨.៣៨០ | ១៥៨.៥៦១ |
| ប្រាក់បញ្ញើសរុប (លានរៀល) | ២.៩៧៤.១៨៣ | ៣.០៣២.៥៥៦ |
| **ព័ត៌មានទូទៅ** | | |
| ចំនួនសាខាបើកដំណើការ | ២៣ | ២៣ |
| ចំនួនបុគ្គលិកសរុប | ៤៨៥ | ៤៤៥ |
| ចំនួនម៉ាស៊ីន អេធីអឹម | ៧០ | ៦៨ |
| ចំនួនម៉ាស៊ីនទូទាត់ | ២១៥ | ២៣៨ |

## ខ. រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី៤ឆ្នាំ២០២២ | | ត្រីមាសទី៤ឆ្នាំ២០២១ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ភាគរយ (%) | ចំនួន (លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ៧៩.០៧៨ | ៩៧,៤៤ | ៧៨.១៤៩ | ៩៨,៥៤ |
| ២ | ចំណូលកម្រៃ និងជើងសារ | ២.០៥១ | ២,៥៣ | ១.១៤៩ | ១,៤៥ |
| ៣ | ចំណូលផ្សេងៗ | ២៣ | ០,០៣ | ៨ | ០,០១ |
| **ចំណូលសរុប** | | **៨១.១៥១** | **១០០** | **៧៩.៣០៦** | **១០០** |

# ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមមើលឧបសម្ពន្ធរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ។

# ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងវិភាគខាងក្រោមផ្តោតលើលទ្ធផលប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ ធនាគារ ភ្នំពេញពាណិជ្ជ ម.ក (PPCBank)និងក្រុមហ៊ុនបុត្រសម្ព័ន្ធ J&A (Cambodia) Investment Co., Ltd គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ដែលត្រូវបានត្រួតពិនិត្យដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុរួមត្រូវបានរៀបចំស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ស.រ.ហ.អ.ក) និងអនុលោមទៅតាមបទបញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍ណែនាំផ្សេងៗដែលចេញដោយធនាគារជាតិនៃកម្ពុជា។

## ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

ធនាគារភ្នំពេញពាណិជ្ជម.ក មានប្រភពចំណូលចំនួន៣ធំៗគឺ ចំណូលការប្រាក់ ចំណូលពីកម្រៃ និងជើងសារនិងចំណូលផ្សេងៗ។

- ចំណូលការប្រាក់រួមមាន ចំណូលការប្រាក់ពីការផ្តល់ឥណទាន ចំណូលការប្រាក់ពីការដាក់ប្រាក់បញ្ញើរនៅធនាគារ និងចំណូលការប្រាក់បានមកពីមូលបត្រវិនិយោគនានា។
- ចំណូលកម្រៃ និងជើងសាររួមមាន កម្រៃសេវាឥណទាន ចំណូលពីការផ្ទេរប្រាក់ក្នុងស្រុក និងបរទេស ចំណូលពីសេវាប្រាក់បញ្ញើ ចំណូលពីសេវាធានា និង ចំណូលពីប័ណ្ណផ្សេងៗ។
- ចំណូលផ្សេងៗ រួមមាន ចំណូលពីអត្រាប្តូរប្រាក់លើការវិនិយោគ និងចំណូលផ្សេងៗទៀត។

### ២. ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល | ត្រីមាសទី៤ឆ្នាំ២០២២ | | ត្រីមាសទី៤ឆ្នាំ២០២១ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ភាគរយ (%) | ចំនួន(លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ៧៩.០៧៨ | ៩៧,៤៤ | ៧៨.១៤៩ | ៩៨,៥៤ |
| ២ | ចំណូលកម្រៃ និងជើងសារ | ២.០៥១ | ២,៥៣ | ១.១៤៩ | ១,៤៥ |
| ៣ | ចំណូលផ្សេងៗ | ២៣ | ០,០៣ | ៨ | ០,០១ |
| ចំណូលសរុប | | ៨១.១៥១ | ១០០ | ៧៩.៣០៦ | ១០០ |

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ទទួលបានចំណូលភាគច្រើនមកពីការប្រាក់ ដែលមាន ៩៧% នៃប្រាក់ចំណូលសរុបក្នុងត្រីមាសទី៤ ឆ្នាំ២០២២។

## ៣. ការវិភាគគម្លាតចំណេញដុល

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានរៀបចំរបាយការណ៍លទ្ធផលរួមរបស់ខ្លួនក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីប្រាក់ចំណេញដុល ប៉ុន្តែទម្រង់របាយការណ៍នេះអាចបង្ហាញលើចំណេញការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុបដកនឹងចំណាយការប្រាក់ដែលនឹងត្រូវយកមកពិភាក្សានៅក្នុងចំណុចបន្ទាប់ការវិភាគចំណេញ(ខាត) មុនបង់ពន្ធ។

## ៤. ការវិភាគចំណេញ (ខាត) មុនបង់ពន្ធ

| សង្ខេបនៃរបាយការន៏ចំនេញខាត | ត្រីមាសទី៤ ឆ្នាំ២០២២ (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២១ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ចំណូលពីការប្រាក់ | ៧៩.០៧៨ | ៧៨.១៤៩ | ៩២៩ | ១,១៩ |
| ចំណាយលើការប្រាក់ | (២៩.១២៥) | (២៤.៨៩៣) | (៤.២៣២) | ១៧,០០ |
| **ចំណូលមកពីការប្រាក់សុទ្ធ** | **៤៩.៩៥២** | **៥៣.២៥៦** | **(៣.៣០៣)** | **(៦,២០)** |
| ចំណូលកម្រៃ និងជើងសារ | ២.០៥១ | ១.១៤៩ | ៩០២ | ៧៨,៤៥ |
| ចំណាយកម្រៃ និងជើងសារ | (១.០៤៧) | (១.២៨៦) | ២៣៩ | (១៨,៦២) |
| **ចំណូលកម្រៃនិងជើងសារសុទ្ធ** | **១.០០៥** | **(១៣៧)** | **១.១៤១** | **(៨៣៥,០៦)** |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២៣ | ៨ | ១៥ | ១៨៥,៤៣ |
| ចំណាយបុគ្គលិក | (៨.៧២៣) | (៩.៣៦៩) | ៦៤៦ | (៦,៩០) |
| ចំណាយប្រតិបត្តិការ | (៨.១១១) | (៧.០២១) | (១.០៩០) | ១៥,៥២ |
| ចំណាយរំលស់ | (៧.៣៤៧) | (៧.៩៤៨) | ៦០១ | (៧,៥៦) |
| **ប្រាក់ចំណេញពីប្រតិបត្តិការ** | **២៦.៧៩៨** | **២៨.៧៨៩** | **(១.៩៩០)** | **(៦,៩១)** |
| ការខាតបង់លើឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ | (១.១៣១) | ៦២៦ | (១.៧៥៦) | (២៨០,៦៧) |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **២៥.៦៦៨** | **២៩.៤១៤** | **(៣.៧៤៧)** | **(១២,៧៤)** |

ក្នុងត្រីមាសទី៤ ឆ្នាំ២០២២ ប្រាក់ចំណេញមុនបង់ពន្ធមានចំនួន ២៥.៦៦៨លានរៀល (១២,៧% តិចជាងប្រៀបធៀបទៅនឹងត្រីមាសទី៤ ឆ្នាំ២០២១) ។ ការថយចុះនៃប្រាក់ចំណេញគឺដោយសារការកើនឡើងនៃចំណាយការប្រាក់ និងការកើនឡើងនៃចំណាយប្រតិបត្តិការ។

## ៥. ការវិភាគចំណេញ (ខាត) ក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៍ចំណេញខាត | ត្រីមាសទី៤ ឆ្នាំ២០២២ (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២១ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ២៥.៦៦៨ | ២៩.៤១៤ | (៣.៧៤៧) | (១២,៧៤) |
| ចំណាយពន្ធលើប្រាក់ចំណូល | (៥.០៧០) | (៥.៩៦៨) | ៨៩៨ | (១៥,០៥) |
| **ប្រាក់ចំណេញសុទ្ធក្នុងគ្រា** | **២០.៥៩៨** | **២៣.៤៤៧** | **(២.៨៤៨)** | **(១២,១៥)** |

ក្នុងត្រីមាសទី៤ ឆ្នាំ២០២២ ប្រាក់ចំណេញបន្ទាប់ពីបង់ពន្ធមានចំនួន ២០,៥៩៨លានរៀល ដែលបានថយចុះ ១២% ប្រៀបធៀបទៅនឹងត្រីមាសទី៤ ឆ្នាំ២០២១ ការថយចុះនេះមកពីការប្រែលប្រួលដូចបានបកស្រាយក្នុងចំនុច៤ (ការវិភាគចំណេញ (ខាត) មុនបង់ពន្ធ)។

## ៦. ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៍ចំណេញខាត | ត្រីមាសទី៤ ឆ្នាំ២០២២ (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២១ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញសុទ្ធក្នុងគ្រា | ២០.៥៩៨ | ២៣.៤៤៧ | (២.៨៤៨) | (១២,១៥) |
| ការខាតលម្អិតផ្សេងៗ | (៨៩) | (៣០១) | ២១២ | (៧០,៤៦) |
| **ប្រាក់ចំណេញលម្អិតសរុប** | **២០.៥០៩** | **២៣.១៤៦** | **(២.៦៣៧)** | **(១១,៣៩)** |

## ៧. ការវិភាគកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិញ្ញវត្ថុ

នៅពេលដែលធនាគារកណ្តាលនៅទូទាំងពិភពលោកដំឡើងអត្រាការប្រាក់ក្នុងពេលដំណាលគ្នាដើម្បីឆ្លើយតបទៅនឹងអតិផរណា ពិភពលោកអាចនឹងឈានឆ្ពោះទៅរកវិបត្តិសេដ្ឋកិច្ចសកលនាឆ្នាំ២០២៣នេះ និងវិបត្តិហិរញ្ញវត្ថុជាច្រើនទៀតនៅក្នុងទីផ្សារដែលកំពុងរីកចម្រើន និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ ដែលនឹងធ្វើឱ្យពួកគេអាចមានវិបត្តិយូរអង្វែង នេះបើយោងតាមសេចក្តីរាយការណ៍ថ្មីមួយសិក្សាដោយធនាគារពិភពលោក។

ធនាគារកណ្តាលនៅជុំវិញពិភពលោកបាននឹងកំពុងដំឡើងអត្រាការប្រាក់នៅឆ្នាំនេះជាមួយនឹងកម្រិតនៃភាពស៊ីសង្វាក់គ្នាដែលមិនត្រូវបានគេមើលឃើញក្នុងរយៈពេលប្រាំទសវត្សរ៍ចុងក្រោយនេះ ដែលជានិន្នាការដែលទំនងជានឹងបន្តបានល្អនៅឆ្នាំក្រោយ។ ប៉ុន្តែគន្លងដែលរំពឹងទុកនាពេលបច្ចុប្បន្ននៃ

ការកើនឡើងអត្រាការប្រាក់ និងសកម្មភាពគោលនយោបាយផ្សេងទៀត ប្រហែលជាមិនគ្រប់គ្រាន់ក្នុងការធ្វើឱ្យអតិផរណាសកលធ្លាក់ចុះដល់កម្រិតដែលមានមុនពេលជំងឺរាតត្បាត កូវីត១៩ នោះទេ។

ទោះជាយ៉ាងណាក៏ដោយ អ្នកគ្រប់គ្រងយល់ឃើញថា សកម្មភាពរបស់ក្រុម និងធនាគារអាចមានភាពយឺតយ៉ាវក្នុងរយៈពេលដ៏ខ្លីនេះ ប៉ុន្តែនឹងមិននាំឱ្យមានបញ្ហាគួរឲ្យព្រួយបារម្ភនោះទេ ដោយសារទំហំនៃប្រតិបត្តិការ កម្រិតប្រាក់ចំណេញបច្ចុប្បន្ន និងផ្នែកសាច់ប្រាក់ងាយស្រួលរបស់ក្រុម និងធនាគារ។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ការព្យាករណ៍កំណើនសេដ្ឋកិច្ចពិភពលោកឡើងវិញដោយ (IMF) នាខែមករា ឆ្នាំ២០២៣ ព្យាករណ៍ថា កំណើនសេដ្ឋកិច្ចសកលនឹងធ្លាក់ចុះមកត្រឹម ២,៩ ភាគរយនៅឆ្នាំ ២០២៣ ប៉ុន្តែកើនឡើងដល់ ៣,១ ភាគរយនៅឆ្នាំ ២០២៤។ ការព្យាករណ៍ ឆ្នាំ២០២៣ គឺ ០,២ ភាគរយខ្ពស់ជាងការព្យាករណ៍នៅក្នុងទស្សនវិស័យសេដ្ឋកិច្ចពិភពលោកនាខែតុលា ឆ្នាំ២០២២ ប៉ុន្តែទាបជាងមធ្យមភាគដែលធ្លាប់មាន ៣,៨ ភាគរយ។ ការកើនឡើងអត្រាការប្រាក់ និងសង្គ្រាមនៅអ៊ុយក្រែននៅតែបន្តដាក់សម្ពាធមកលើសកម្មភាពសេដ្ឋកិច្ច។ ការបើកដំណើរការឡើងវិញរបស់ប្រទេសចិននាពេលថ្មីៗនេះ បានត្រួសត្រាយផ្លូវសម្រាប់ការងើបឡើងវិញលឿនជាងការរំពឹងទុក។ អតិផរណាសកលត្រូវបានគេរំពឹងថានឹងធ្លាក់ចុះមក ៦,៦ ភាគរយនៅឆ្នាំ ២០២៣ និង ៤,៣ ភាគរយនៅឆ្នាំ ២០២៤ នៅតែខ្ពស់ជាងកម្រិតដែលមានមុនការរាតត្បាតជាសកលនៃជម្ងឺ កូវីត១៩។

ជាមួយនឹងស្ថានភាពនេះ វាមានឥទ្ធិពលខ្លះទៅលើលទ្ធផលហិរញ្ញវត្ថុរបស់ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ដូច្នេះផលិតផល និងសេវាកម្មថ្មីនឹងត្រូវបន្ថែមដើម្បីរក្សាកំណើនធនាគារ។ ជាលទ្ធផល ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានបង្កើត និងបន្ថែមសេវាកម្មមួយចំនួនដូចខាងក្រោម៖

- ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានបង្កើតសេវាកម្មថ្មីមួយសម្រាប់ការមានគណនីនិម្មិតអាចទទួលបានការទូទាត់ពីប្រព័ន្ធ Bakong Transfer ។ អតិថិជន និងសហគ្រាសដែលប្រើប្រាស់គណនីនិម្មិតរបស់យើងសម្រាប់ការប្រមូលការទូទាត់សម្រាប់អាជីវកម្មរបស់ពួកគេអាចទទួលបានការទូទាត់ពីសមាជិកបាគងណាមួយបន្ថែមលើបណ្តាញសេវារបស់ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ដែលមានស្រាប់។

- ដើម្បីធ្វើឲ្យប្រសើរឡើងទៀតសម្រាប់ប្រព័ន្ធឌីជីថល ភាពអាចរកបាននៃមុខងារបន្ថែម និងដំណើរការផ្ទេរប្រាក់ថ្មីត្រូវបានបន្ថែមនៅលើ PPCBank Mobile ។
- PPWSA (រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ) និង EDC (អគ្គិសនីកម្ពុជា) Bill Payment ត្រូវបានដាក់បន្ថែមឲ្យតំណើរការនៅលើ smartBiz ដោយមិនគិតថ្លៃ។ អតិថិជនសាជីវកម្មអាចធ្វើការទូទាត់ PPWSA និង EDC តាមអ៊ីនធឺណិតភ្លាមៗពី smartBiz ដោយមិនចាំបាច់ទៅធ្វើប្រតិតបត្តិការសូម្បីតែសាខាដែលនៅជិតបំផុតរបស់ពួកគេ។
- ដាក់ឲ្យតំណើរការម៉ាស៊ីន CRM ដែលធ្វើឱ្យអតិថិជនកាន់តែមានភាពងាយស្រួល និងរហ័សក្នុងការដាក់ប្រាក់ចូលក្នុងគណនីធនាគារបានគ្រប់ពេលវេលានៅពេលណាក៏បាន។
- បើកដំណើរការ "គណនីប្រាក់រៀលភ្ជាប់ទៅកាត" ដែលអាចឱ្យអ្នកកាន់គណនីប្រាក់រៀលអាចភ្ជាប់គណនីរបស់ពួកគេជាមួយប័ណ្ណឥណពន្ធ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក និងធ្វើប្រតិបត្តិការតាមរយៈម៉ាស៊ីន ATM និង POS បានគ្រប់ទីកន្លែងទាំងអស់។

## ២. ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនមានផលប៉ះពាល់ដល់ធនាគារឡើយ ។

## ៣. ការវិភាគលើពន្ធ

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនត្រូវមានកាតព្វកិច្ចបង់ពន្ធដូចបានកំណត់ក្នុងបទប្បញ្ញត្តិស្តីពីពន្ធដាររបស់ព្រះរាជាណាចក្រកម្ពុជា។

ជាមួយនឹងកាតព្វកិច្ចពន្ធ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានទទួលវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ "**មាស**" ពីអគ្គនាយដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ ២០២២ និង២០២៣។

## ៤. ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

សេដ្ឋកិច្ចពិភពលោកកំពុងមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ ចំពេលពីការកើនឡើងនៃអតិផរណា អាចនឹងមានផលប៉ះពាល់ខ្លះដល់លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ក្នុងត្រីមាសទី៤ ឆ្នាំ២០២២ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក មានការថយចុះនៃចំណូល ដែលមានចំណូលការប្រាក់សុទ្ធសរុប ៤៩.៩៥២លានរៀល ដែលស្មើនឹងការថយចុះ ៦,២% ធៀបនឹងរយៈពេល ដូចគ្នាក្នុងឆ្នាំ២០២១។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ស្ថានភាពចំហនៃរូបិយប័ណ្ណបរទេស ត្រូវបានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ជាប្រចាំតាមបទបញ្ញត្តិ ដើម្បីអាចវាស់វែង និងធានាថាវានឹងមិនធ្វើឲ្យប៉ះពាល់ដល់និរន្តរភាពនៃប្រាក់ចំណេញរបស់ធនាគារ។

ពាក់ព័ន្ធនឹងអត្រាការប្រាក់ធនាគារកំណត់អត្រាការប្រាក់ថេរសម្រាប់ប្រាក់បញ្ញើរ និងប្រាក់កម្ចីរបស់ខ្លួនសម្រាប់ប្រតិបត្តិការអាជីវកម្ម។ ដូច្នេះធនាគារមិនមានទទួលរងហានិភ័យជាសារវន្តទាក់ទងនឹងអត្រាការប្រាក់មកលើលទ្ធផលនៃប្រតិបត្តិការអាជីវកម្មធនាគារនោះទេ ។

ឥទ្ធិពលនៃថ្លៃទំនិញ មិនមានផលប៉ះពាល់មកលើលទ្ធផលប្រតិបត្តិរបស់ធនាគារឡើយ ។

## ង. ផលប៉ះពាល់អតិផរណា

អតិផរណាមានកម្រិតដល់ ៥,៣% ក្នុងឆ្នាំ ២០២២ ដែលមានអត្រា ២,៩% ខ្ពស់ជាងប្រៀបធៀបទៅនឹងឆ្នាំមុន ២០២១ ដោយសារកំណើនថ្លៃក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ និងម្ហូបអាហារ។ ជាមួយអត្រាអតិផរណានេះមិនមានផលប៉ះពាល់ណាមួយជាសារវន្តមកលើលទ្ធផលប្រតិបត្តិការអាជីវកម្មរបស់ធនាគារនៅឡើយទេ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងហិរញ្ញវត្ថុ របស់រដ្ឋាភិបាល

យោងតាមប្រកាសថ្មីរបស់ធនាគារជាតិនៃកម្ពុជា ធ៧.០២៣.០០៥ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវរក្សាប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើ និងប្រាក់កម្ចី ក្នុងសមតុល្យមធ្យមប្រចាំថ្ងៃជាមួយធនាគារជាតិ នៃកម្ពុជា ស្របតាមកាលបរិច្ឆេទ និងកម្រិតដូចខាងក្រោម៖

- ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០២៣ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២៣ ប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណត្រូវមានកម្រិត ៩% (ប្រាំបួនភាគរយ)

- ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០២៤ តទៅ ប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណត្រូវមានកម្រិត ១២,៥% (ដប់ពីរក្បៀសប្រាំភាគរយ)។

ចំណែកឯប្រាក់បម្រុងកាតព្វកិច្ចជារូបិយវត្ថុជាតិ គ្រឹះស្ថានត្រូវរក្សាអត្រានៅកម្រិត ៧% (ប្រាំពីរភាគរយ) ដដែល។

ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជា ក៏បានចេញសេចក្តីជូនដំណឹងថ្មីលេខ ធ៧.០២៣.០២២ ស.ជ.ណ ដល់គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ត្រូវបំពេញទ្រនាប់ដើមទុនខនសើរវេសិន តាមកម្រិតអនុបាតនិងកាលបរិច្ឆេទ ដូចខាងក្រោម៖

- ១,២៥% (មួយក្បៀសម្ភៃប្រាំភាគរយ) ត្រឹមថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២៣ និង
- ២,៥% (ពីរក្បៀសប្រាំភាគរយ) ត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២៣

ដោយឡែក ចំពោះអនុបាតទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល គ្រឹះស្ថាននៅរក្សាកម្រិត ០% (សូន្យភាគរយ) ដដែល។

**ហត្ថលេខាអភិបាលរបស់ធនាគារភ្នំពេញពាណិជ្ជ ម.ក**

ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣

បានអាន និងឯកភាព

លោក YIM. Yong Taick

ប្រធានក្រុមប្រឹក្សាភិបាល

PPCBank